**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ០៥៤៩ ព.ណ.រប.....

# សេចក្តីណែនាំបន្ថែម
# ស្តីពី
# វិធានបន្ទាន់ក្នុងការទប់ស្កាត់ការរាតត្បាត នៃជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ សម្រាប់ថ្នាក់ដឹកនាំ អង្គភាពក្រោមឱវាទក្រសួងពាណិជ្ជកម្ម

យោងតាមបទបញ្ជារបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** វេលាម៉ោង២១:១០នាទីយប់ ថ្ងៃទី៨ ខែមីនា ឆ្នាំ២០២១ និងស្របតាមវិធានការណ៍ណែនាំរបស់ក្រសួងសុខាភិបាល ដើម្បីចូលរួមបង្ការ និងទប់ស្កាត់ការរាតត្បាត នៃជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ លក្ខណៈទ្រង់ទ្រាយធំ ក្រសួងពាណិជ្ជកម្ម សូមធ្វើការណែនាំបន្ថែមលើសេចក្តីណែនាំលេខ០៤១៨ ព.ណ រប ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងគ្រប់អង្គភាពចំណុះក្រោមឱវាទត្រូវអនុវត្តនូវវិធានមួយចំនួនដូចតទៅ៖

១. ត្រូវផ្អាកជាបណ្តោះអាសន្ននូវការប្រជុំ ឬការជួបជុំ រយៈពេល១សប្តាហ៍ ក្នុងករណីចាំបាច់អាចរៀបចំប្រជុំតាមប្រព័ន្ធវីដេអូ។

២. គ្រប់អង្គភាពទាំងអស់ត្រូវចាត់មន្ត្រីមកបំពេញការងារយ៉ាងច្រើនបំផុត ១០ភាគរយ ក្រៅពីនោះអនុញ្ញាតឱ្យបំពេញការងារនៅផ្ទះ តាមប្រព័ន្ធវីដេអូរហូតដល់មានការចេញបទបញ្ជាថ្មីរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា។

៣. ប្រសិនបើមានការសង្ស័យថាបានប៉ះពាល់អ្នកជំងឺកូវីដ-១៩ ដោយផ្ទាល់ ឬប្រយោល ឬមានរោគសញ្ញាសង្ស័យជំងឺកូវីដ-១៩ ឬមានជំងឺផ្តាសាយដែលសង្ស័យ ត្រូវចូលរួមធ្វើតេស្តវិភាគរកវីរុសកូវីដ-១៩ និងត្រូវដាក់ខ្លួនឱ្យនៅដាច់ដោយឡែកពីគេភ្លាមៗ។

ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងគ្រប់អង្គភាពចំណុះក្រសួងពាណិជ្ជកម្មទាំងអស់ ត្រូវចូលរួមអនុវត្តតាមសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាព ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃអង្គារ ១១រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមីនា ឆ្នាំ២០២១

ក្រសួងពាណិជ្ជកម្ម